**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៦១ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ចេញពីផែនទីតម្រូវព្រៃឈើ និងធ្វើអនុបយោគ មកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីសរុបចំនួន ៦៧៥១,២៩ ហិកតា នៅស្រុក ភ្នំក្រវាញ ស្រុកក្រគរ ស្រុកបាកាន និងក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ និងធ្វើប្រទានកម្មផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧៣៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ២២៨៤ ខ.ពស ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់
- តាមសំណើលេខ២៣០២ ខ.ពស ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## **សម្រេច**

**មាត្រា ១.**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវចំណែកផ្ទៃដីសរុបចំនួន ៦៧៥១,២៩ ហិកតា (ប្រាំមួយពាន់ប្រាំពីររយហាសិបមួយហិកតា និងម្ភៃប្រាំបួនអា) ដែលក្នុងនោះមាន ៖

(ក). ផ្ទៃដីទំហំ ៥៥១,៨៣ ហិកតា (បួនរយហាសិបមួយហិកតានិងប៉ែតសិបបីអា) មានទីតាំងភូមិប៉ែនឃុំលាច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ត្រូវកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ ក្រុមហ៊ុន ភាពីម៉ិច តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ-I (I.1-I.2) នៃអនុក្រឹត្យនេះ។

(ខ). ផ្ទៃដីទំហំ ១.៥៧៥,៩៥ ហិកតា (មួយពាន់ប្រាំរយសែសិបប្រាំហិកតានិងកៅសិបប្រាំអា) មានទីតាំងស្ថិតនៅភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ត្រូវកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ ក្រុមហ៊ុន ភាពីម៉ិច តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ-II (II.1-II.10) នៃអនុក្រឹត្យនេះ។

(គ). ផ្ទៃដីទំហំសរុបចំនួន ៧០៨,១០ ហិកតា (ប្រាំពីររយប្រាំបីហិកតានិងដប់អា) មានទីតាំងស្ថិតក្នុងភូមិអូរអាចម៍កុក និងភូមិក្រាំងធំ ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ-III (III.1-III.2) នៃអនុក្រឹត្យនេះ ដែលក្នុងនោះ ៖

*គ.១).* ផ្ទៃដីទំហំ ១៨៦,៩៤ ហិកតា (មួយរយប៉ែតសិបប្រាំមួយហិកតានិងកៅសិបបួនអា) ត្រូវកាត់ចេញពីក្រុមហ៊ុនភាពីម៉ិច និង

*គ.២).* ផ្ទៃដីទំហំ ៥២១,១៦ ហិកតា (ប្រាំរយម្ភៃមួយហិកតានិងដប់ប្រាំមួយអា) ត្រូវកាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២

(ឃ). ផ្ទៃដីទំហំសរុបចំនួន ១១៩៣,៤០ ហិកតា (មួយពាន់មួយរយកៅសិបបីហិកតា និងសែសិបអា) មានទីតាំងស្ថិតក្នុងភូមិព្រៃកន្ទួត និងភូមិតាំងគោក ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ-IV នៃអនុក្រឹត្យនេះ ដែលក្នុងនោះ ៖

*ឃ.១).* ផ្ទៃដីទំហំ ៨៩៣,៦១ ហិកតា (ប្រាំបីរយកៅសិបបីហិកតនិងហុកសិបមួយអា) ត្រូវកាត់ចេញពីក្រុមហ៊ុន តូចហ៊ាវ អ៊ិនខូបរ៉េស៊ិន និង

*ឃ.២).* ផ្ទៃដីទំហំ ២៩៩,៧៩ ហិកតា (ពីររយកៅសិបប្រាំបួនហិកតានិងចិតសិបប្រាំបួនអា) ត្រូវកាត់ចេញពីដីព្រៃសម្បទាន

(ង). ផ្ទៃដីទំហំ ២៨៥២,០១ ហិកតា (ពីរពាន់ប្រាំបីរយហាសិបពីរហិកតា និងមួយអា) មានទីតាំងភូមិទួលម្កាក់ សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ-V នៃអនុក្រឹត្យនេះ ដែលក្នុងនោះ ៖

*ង.១).* ផ្ទៃដីទំហំ ៨៤៧,៣៦ ហិកតា (ប្រាំបីរយសែសិបប្រាំពីរហិកតានិងសាមសិបប្រាំមួយអា) ត្រូវកាត់ចេញពីក្រុមហ៊ុនភាពីម៉ិច និង

*ង.២).* ផ្ទៃដីទំហំ ២០០៤,៦៥ ហិកតា (ពីរពាន់បួនហិកតានិងហុកសិបប្រាំអា) ត្រូវកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ ។

**មាត្រា ២..**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មដោយផ្តល់នូវសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ហើយដែលក្នុងនោះ៖

- ត្រូវធ្វើប្រទានកម្មដោយផ្តល់នូវសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងភូមិប៉ែន ឃុំលាច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ចំនួន ១៤៣ (មួយរយសែសិបបី) គ្រួសារ លើផ្ទៃដីដូចមានចែងក្នុងមាត្រា១(ក) ខាងលើ។
- ត្រូវធ្វើប្រទានកម្មដោយផ្តល់នូវសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងភូមិសាយ ឃុំប្រម៉ោយ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ចំនួន ៥៤៣ (ប្រាំរយសែសិបបី) គ្រួសារ លើផ្ទៃដីដូចមានចែងក្នុងមាត្រា១(ខ) ខាងលើ។
- ត្រូវធ្វើប្រទានកម្មដោយផ្តល់នូវសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងភូមិអូរអាចម៍កុក ភូមិក្រាំងធំ ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់៖
  - ចំនួន ៧១ (ចិតសិបមួយ) គ្រួសារ លើផ្ទៃដីដូចមានចែងក្នុងមាត្រា ១(គ.១) ខាងលើ។
  - ចំនួន ២៧៤ (ពីររយចិតសិបបួន)គ្រួសារ លើផ្ទៃដីដូចមានចែងក្នុងមាត្រា ១(គ.២) ខាងលើ។
- ត្រូវធ្វើប្រទានកម្មដោយផ្តល់នូវសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងភូមិព្រៃកន្ទួត និងភូមិតាំងគោក ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ ៖
  - ចំនួន ២៩០ (ពីររយកៅសិប)គ្រួសារ លើផ្ទៃដីដូចមានចែងក្នុងមាត្រា ១(ឃ.១) ខាងលើ។
  - ចំនួន ១៩៧ (មួយរយកៅសិបប្រាំពីរ) គ្រួសារ លើផ្ទៃដីដូចមានចែងក្នុងមាត្រា ១(ឃ.២) ខាងលើ។
- ត្រូវធ្វើប្រទានកម្មដោយផ្តល់នូវសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងភូមិទួលម្កាក់ សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ៖

- ចំនួន ៤០៧ (បួនរយប្រាំពីរ)គ្រួសារ លើផ្ទៃដីដូចមានចែងក្នុងមាត្រា ១(ង.១) ខាងលើ។
- ចំនួន ៨១០ (ប្រាំបីរយដប់) គ្រួសារ លើផ្ទៃដីដូចមានចែងក្នុងមាត្រា ១(ង.២) ខាងលើ។

**មាត្រា ៣ .-**

- ត្រូវផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៩២ គ្រួសារ ចំពោះក្បាលដីចំនួន ១៧៧ ក្បាលដី និង ២៥ ក្បាលដី ជាដីរដ្ឋ រួមមានដីសាលារៀន ០២ ក្បាលដី ដីស្រះទឹក ០១ ក្បាលដី និងដីព្រៃបំរុងទុក ២២ ក្បាលដី នៅភូមិប៉ែន ឃុំលាច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ និង
- ត្រូវផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៥៨៣ គ្រួសារ ចំពោះក្បាលដីចំនួន ៨៣៧ ក្បាលដី និងដីវត្ត ០១ ក្បាលដី ព្រមទាំង ៤៦ក្បាលដី ដែលក្នុងនោះ ដីសាលារៀន ០២ ក្បាលដី ដីស្នាក់ការភូមិ ០១ ក្បាលដី ដីមណ្ឌលសុខភាព ០១ ក្បាលដី ដីព្រៃសហគមន៍ ០១ ក្បាលដី និងដីព្រៃបំរុងទុក ៤១ ក្បាលដី នៅភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

**មាត្រា ៤ .-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមនៅក្នុងមូលដ្ឋាន។

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល ៖*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋាន រដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*